**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសនីយ៍ និង ទូរគមនាគមន៍

“....ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព”

លេខ : ៥៩១ បទ-នគរប

# សេចក្តីជូនដំណឹង

## ស្តីពីការប្រើប្រាស់រលកអាកាសវិទ្យុ និងបរិក្ខារវិទ្យុគមនាគមន៍

យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៦ ដែលមានខ្លឹមសារថា៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**គប្បីលុប ចោលប្រេកង់ខ្លះ ដែលក្រុមហ៊ុនខ្លះមិនវិនិយោគ យកមកប្រគល់ជូនក្រុមហ៊ុន ដែលវិនិយោគពិតប្រាកដ** ។ ឆ្លងតាម ន័យនេះក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍សូមជំរាបថា៖ ដើម្បីជៀសវាងដល់ការ**ឆ្លងរំខាន ឬ បាត់បង់ប្រេកង់** (រលកអាកាសវិទ្យុ) និងដើម្បីឱ្យការធ្វើអាជីវកម្មលើបរិក្ខារវិទ្យុគមនាគមន៍ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងសហភាព ទូរគមនាគមន៍អន្តរជាតិ **ITU** (International Telecommunication Union) ផងនោះ សូមបណ្តាអង្គភាព ក្រុមហ៊ុន អាជីវកម្ម ស្ថានីយវិទ្យុនិងទូរទស្សន៍ ដែលបាននិងកំពុងប្រើប្រាស់ប្រេកង់ស៍ (រលកអាកាសវិទ្យុ) ឬ ធ្វើអាជីវកម្មបរិក្ខារវិទ្យុ គមនាគមន៍ដោយគ្មានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ឬវិញ្ញាបនប័ត្រ ជាភ្នាក់ងារនាំចូល លក់ ឬ ជួសជុលទាំងអស់ មក៖

១- បំពេញបែបបទដើម្បីទទួលយកអាជ្ញាប័ណ្ណប្រេកង់ស៍ ឬមកប្តូរយកអាជ្ញាប័ណ្ណថ្មី (ក្នុងករណីហួសកាលបរិច្ឆេទ)

២- បំពេញបែបបទដើម្បីទទួលយកលិខិតអនុញ្ញាត ឬ វិញ្ញាបនប័ត្រ ជាភ្នាក់ងារនាំចូល លក់ ឬ ជួសជុលបរិក្ខារវិទ្យុគមនាគមន៍នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុ ទូរស័ព្ទលេខ ០២៣ ៧២២ ៣១១ ) ឬ នៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍គ្រប់ខេត្ត ឱ្យបានមុនថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៩ ជាកំហិត ។

ក្នុងករណីមិនគោរពតាមសេចក្តីជូនដំណឹងនេះទេ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សហការជាមួយក្រសួងមានសមត្ថកិច្ច អាជ្ញាធរដែនដី និងចាត់វិធានការណ៍យ៉ាង់ម៉ឺងម៉ាត់បំផុត ចុះត្រួតពិនិត្យ ដើម្បីដកហូតនូវរលកអាកាសវិទ្យុ ឬ បរិក្ខារវិទ្យុ គមនាគមន៍ ដែលកំពុងដំណើរការដោយមិនទទួលខុសត្រូវលើការខូចខាតឬបាត់បង់នោះឡើយ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សង្ឃឹមជឿជាក់ថា ម្ចាស់ អង្គភាព ក្រសួងអាជីវកម្ម ព្រមទាំងស្ថានីយ និងទូរទស្សន៍ ទាំងអស់ នឹងអនុវត្តន៍តាមសេចក្តីជូនដំណឹងនេះក្នុងការបំពេញកាតព្វកិច្ចដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩

**រដ្ឋមន្ត្រី**

**សូរ ឃុន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋមន្ត្រី
  “ដើម្បីជូនជ្រាបជាព័ត៌មាន”
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់អង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- គ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍
  “ដើម្បីសហការ អនុវត្តន៍”
- ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ : លោក ឈឹម ទីណា